# គោលការណ៍វិស្សលប្ល័វឺង

## គោលនយោបាយ

ធនាគារគ្មានការលើកលែង នៅលើទម្រង់នៃការប្រព្រឹត្តិខុសឆ្គង ឬការរំលោភសិទ្ធអាជីវកម្ម ដែលស្របទៅ តាមក្រម សីលធម៌ និងគុណតម្លៃរួម។

ជាផ្នែកមួយនៃគោលការណ៍នេះ រាល់ទម្រង់នៃ ការលួចបន្លំ ការសូកប៉ាន់ ឬអំពើពុករលួយ មិនត្រូវទទួលស្គាល់ពី ធនាគារ ដោយមិនគិតពីអត្តសញ្ញាណ មុខតំណែងរបស់បុគ្គលដែលពាក់ព័ន្ធ និងការរំលោភណាមួយរបស់បុគ្គលិក ឬដៃគូពាណិជ្ជកម្ម គឺមិនត្រូវបានលើកលែងឡើយ។

រាល់សកម្មភាពក្លែងបន្លំ និងការសូកប៉ាន់ ឬពុករលួយគឺជាបទល្មើសព្រហ្មទណ្ឌ និងជាការរំលោភយ៉ាងច្បាស់ ទៅលើ ក្រមសីលធម៌ និងគុណតម្លៃរួម (P.R.I.D.E)។ អាក្បកិរិយា ឬសកម្មភាពដែលផ្ទុយពីគោលការណ៍ និងគុណតម្លៃ របស់ធនាគា ក៏ដូចជា រាល់ការរំលោភបំពានច្បាប់កម្ពុជា និងបទបញ្ញា ណាមួយ គឺត្រូវបានហាមឃាត់យ៉ាងតឹងរ៉ឹង។

រាល់បុគ្គលិកទាំងអស់ គឺត្រូវតែបន្តអនុវត្តស្របទៅតាមបទដ្ឋានខ្ពស់បំផុតនៃសេចក្តីទៀងត្រង់ ឥរិយាបទ ប្រកបដោយ សីលធម៌ វិជ្ជាជីវៈ ស្មោះត្រង់ និងស្មើភាព នៅក្នុងអាជីវកម្មពីមួយថ្ងៃទៅមួយថ្ងៃ និងការរៀបចំប្រតិបត្តិការ។ ម្យ៉ាងទៀតបុគ្គលិកទាំងអស់គឺត្រូវតែប្តេជ្ញាក្នុងការទប់ស្កាត់ បង្អាក់ និងរកឲ្យឃើញនូវទម្រង់នៃការប្រព្រឹត្តមិនត្រឹមត្រូវ ឬអាក្បកិរិយា គ្មានក្រមសីលធម៌ដោយមិនមានកំណត់ចំពោះការលួចបន្លំ សកម្មភាពការប្រឆាំងនឹងការប្រកួតប្រជែង ការលួចទិន្នន័យ ផ្ទាល់ខ្លួន ការបង្ហាញនូវពត៌មាន អតិជនដោយគ្មានការអនុញ្ញាត ការសូកប៉ាន់ និងអំពើពុករលួយដែលពាក់ព័ន្ធនឹងធនាគារ។

## ការការពារអ្នកអនុវត្តគោលការណ៍វិស្សលប្ល័វឺង

ធនាគារទទួលស្គាល់ថា និយោជិកគឺអ្នកនាំមុខចំពោះព័ត៌មានដែលពាក់ព័ន្ធ ហើយជាទូទៅអ្នកដែលរកឃើញនូវកំហុសឆ្គង ឬអំពើមិនត្រឹមត្រូវមុនគេនៅក្នុងធនាគារ។

ការព្រួយបារម្ភមួយចំនួនអាចមិនសមហេតុផល និងអាចត្រូវបានដោះស្រាយដោយការយោគយល់។ ផ្ទុយទៅវិញ ក៏មានការព្រួយបារម្ភដែលអាចសន្និដ្ឋានបានថាជាបញ្ហាតូចតាច ដែលវាអាចឈានដល់បញ្ហាធ្ងន់ធ្ងរពាក់ព័ន្ធនឹង បទឧក្រិដ្ឋ ហើយ ប្រហែលអាចមានផលប៉ះពាល់ទៅលើកេរ្តិ៍ឈ្មោះធនាគារ និងស្ថានភាពហិរញ្ញវត្ថុផងដែរ។

ទោះបីយ៉ាងណាក៏ដោយ សម្រាប់ការភ័យខ្លាចសុវត្ថិភាពផ្ទាល់ខ្លួន ការរើសអើង និងសុវត្ថិភាពការងារ និយោជិកមិនហ៊ាន បញ្ចេញការព្រួយបារម្ភពួកគេ ទាក់ទងទៅនឹងការប្រព្រឹត្តខុសច្បាប់ឬ បញ្ហាមិនប្រតិបត្តិតាម ដែលអាច ឬត្រូវបានប្រព្រឹត្តដោយ អ្នកធ្វើការជាមួយ ឬ មន្ត្រីថ្នាក់លើរបស់ពួកគេ។ ការការពារវិស្សលប្លូវើរ គឺត្រូវបានបញ្ជាក់នូវក្រោមច្បាប់ និងបទបញ្ញត្តិប្រទេសកម្ពុជាដូចខាងក្រោម៖

ក. ប្រកាសស្ដីពីការត្រួតពិនិត្យផ្ទៃក្នុងរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ (២០១០) បានចង្អុលបង្ហាញថា រាល់ខ្សែបណ្ដាញរាយការណ៍គ្រប់គ្រាន់ និងឯករាជ្យគួរត្រូវបានបង្កើតឡើងដើម្បីអនុវត្តគោលការណ៍វិស្សលប្លូវីងយ៉ាងសំងាត់។ ច្បាប់ការពារបុគ្គលត្រូវបង្កើតឡើងដើម្បីផ្ដល់អត្ថប្រយោជន៍ដល់បុគ្គលិកទាំងអស់ ដែលធ្វើការស្មោះត្រង់ និងផ្ដល់ផលប្រយោជន៍រួមដល់ក្រុមហ៊ុន។

ខ. ប្រការ១៣ នៃច្បាប់ប្រឆាំងអំពើពុករលួយ (២០១០) បានចែងច្បាស់ថា អង្គភាពប្រឆាំងអំពើពុករលួយ ត្រូវចាត់វិធានការចាំបាច់ដើម្បីរក្សាសុវត្ថិភាពវិស្សលប្លូវើរ។

## មធ្យោបាយវិស្សលប្លូវីង

ក. របាយការណ៍ និងពាក្យបណ្ដឹងគួរតែបញ្ជូនទៅដោយផ្ទាល់ដល់អ្នកទទួលដែលបានត្រូវតែងតាំងដូចខាងក្រោម៖

អ៊ីម៉ែល៖ kh.whistleblowing@rhbgroup.com.kh

ខ. ធនាគារអាននឹងចូលរួមជាមួយអ្នកផ្ដល់សេវាកម្មខាងក្រៅ ដើម្បីក្លាយជាភាគីដែលត្រូវបានអនុញ្ញាត្ត ជាអ្នកទទួល ដែលបានត្រូវតែងតាំងដោយធនាគារ ដើម្បីទទួលរបាយការណ៍វិស្សលប្លូវីងក្នុងនាមជាគ្រឹះស្ថានធនាគារ បន្ទាប់ពីការ អនុម័តរបស់ក្រុមប្រឹក្សាភិបាល។

គ. ការផ្លាស់ប្ដូរណាមួយនៅក្នុងបញ្ជីដែលបានអនុញ្ញាត្តរបស់អ្នកទទួលដែលបានត្រូវតែងតាំងនឹងត្រូវបង្ហាញក្នុង គោលនយោបាយ ផ្ទៃក្នុង ការណែនាំ និង/ឬនីតិវិធីដែលពាក់ព័ន្ធ បន្ទាប់ពីការ អនុម័តរបស់ក្រុមប្រឹក្សាភិបាល។